មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦

## ម.ស.ម.ក ចេញផ្សាយរបាយការណ៍បង្ហាញពីការរើសអើងទៅលើអ្នកប្តូរភេទជាស្ត្រីក្នុងកម្រិតគួរឱ្យព្រួយបារម្ភ នៅកម្ពុជា និងស្នើរដ្ឋាភិបាលចាត់វិធានការបន្ទាន់ដើម្បីការពារសិទ្ធិរបស់អ្នកប្តូរភេទ

នៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦ នេះ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ចេញផ្សាយរបាយការណ៍ស្រាវជ្រាវមានចំណងជើងថា «*ការរើសអើងលើអ្នកប្តូរភេទជាស្ត្រីនៅតាមទីប្រជុំជននៅក្នុងព្រះរាជាណាចក្រកម្ពុជា*» («របាយការណ៍»)។ របាយការណ៍នេះអាចទាញយកបានទាំងជាភាសាខ្មែរ គេហទំព័រ និងអង់គ្លេស គេហទំព័ នៅលើ របស់ ម.ស.ម.ក។ របាយការណ៍នេះធ្វើឡើងដោយគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ ម.ស.ម.ក និងជាសមិទ្ធផលនៃការស្រាវជ្រាវនៅតាមទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា («កម្ពុជា») ពាក់ព័ន្ធនឹងការកើតឡើងជាទូទៅ និងទម្រង់នៃការរើសអើងទៅលើអ្នកប្តូរភេទជាស្ត្រី («អ្នកប្តូរភេទ»)។

របាយការណ៍នេះផ្អែកទៅលើបេកគំហើញនៃការចុះទៅស្រាវជ្រាវផ្ទាល់របស់ ម.ស.ម.ក ដែលប្រមូលបានតាមរយៈការស្ទង់មតិពីមនុស្សចំនួន ១៣៥នាក់ ក្នុងខែមេសា ឆ្នាំ២០១៦ នៅរាជធានីភ្នំពេញ ខេត្តសៀមរាប ខេត្តព្រះសីហនុ និងខេត្តបាត់ដំបង។ ការស្ទង់មតិនេះបានសាកសួរលើអ្នកប្តូរភេទអំពីបទពិសោធន៍ និងការយល់ឃើញរបស់ពួកគេជុំវិញការរើសអើងផ្អែកលើអត្តសញ្ញាណអ្នកប្តូរភេទ ឬ ការបង្ហាញទំនោរភេទរបស់ពួកគេ ដែលការរើសអើងនេះអាចប្រព្រឹត្តដោយតួអង្គរដ្ឋ (ដូចជា នគរបាល អាជ្ញាធរមូលដ្ឋាន និងតាមសាលារៀន) និងតួអង្គមិនមែនរដ្ឋ (ដូចជា គ្រួសារ កន្លែងការងារ និងតួអង្គក្នុងទំនាក់ទំនងផ្សេងៗទៀត)។ របាយការណ៍នេះក៏ធ្វើការវិភាគក្នុងបរិបទច្បាប់ សង្គម និងវប្បធម៌នៅក្នុងដំណើរជីវិតរបស់អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជាផងដែរ។

ការស្រាវជ្រាវរបស់ ម.ស.ម.ក បង្ហាញថា អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជាទទួលរងការរើសអើងក្នុងកម្រិតគួរឱ្យព្រួយបារម្ភខ្លាំង។ អ្នកប្តូរភេទជាស្ត្រីស្ទើរតែទាំងអស់ដែល ម.ស.ម.ក បានស្ទង់មតិ ធ្លាប់ទទួលរងការយាយីមួយចំនួននៅទីសាធារណៈដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេដោយក្នុងករណីជាច្រើនមានអ្នកទទួលរងការគំរាមច្រើនដងនៅក្នុងរយៈពេល១២ខែកន្លងមកនេះ។ ចំនួនអ្នកឆ្លើយតបដែលធ្លាប់ទទួលរងការបំពានដោយពាក្យសម្តី **(៩២%)** អំពើហិង្សាលើរាងកាយ **(៤៣%)** រំលោភបំពានផ្លូវភេទ **(៣១%)** និងរំលោភសេពសន្ថវៈ **(២៥%)** ដោយការបំពានទាំងនេះ

ធ្វើឡើងនៅតាមទីសាធារណៈដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ ដែលនេះបង្ហាញថា នៅតាមដងផ្លូវសាធារណៈក្នុងប្រទេសកម្ពុជាគ្មានសុវត្ថិភាពទាល់តែសោះសម្រាប់អ្នកប្តូរភេទជាស្ត្រី។ ការរើសអើងនៅកន្លែងការងារ គឺជាបញ្ហាធ្ងន់ធ្ងរមួយផ្សេងទៀត ដែលត្រូវបានរកឃើញតាមរយៈការស្រាវជ្រាវនេះ ដោយចំនួន **៣៤%** នៃអ្នកឆ្លើយតបបានរាយការណ៍ថាខ្លួនត្រូវបានបដិសេធទទួលយកឱ្យធ្វើការ និងចំនួន **២៥%** ទៀតបានរាយការណ៍ថាត្រូវបានបណ្តេញចេញពីការងារ ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ។

ការស្រាវជ្រាវនេះបង្ហាញផងដែរថា មានគ្រួសារជាច្រើនពុំបានយល់ដឹង និងមិនទទួលយកសមាជិកគ្រួសារជាអ្នកប្តូរភេទ ក្រោយពេលដែលពួកគេបង្ហាញអាកប្បកិរិយាចេញមកក្រៅ ដោយ**៤៩%** នៃអ្នកឆ្លើយតប បានលើកឡើងថា ពួកគេធ្លាប់មានអារម្មណ៍ចង់ចាកចេញពីផ្ទះ ដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ខ្លួន។ អ្វីដែលគួរឱ្យកត់សម្គាល់ទៅទៀតនោះ ជាងពាក់កណ្តាល (**៥៣%**) នៃគ្រួសាររបស់អ្នកឆ្លើយតបទាំងនោះបានព្យាយាមបង្ខំពួកគេឱ្យរៀបការជាមួយអ្នកដែលមានភេទផ្ទុយគ្នា។

ការរកឃើញគួរឱ្យព្រួយបារម្ភខ្លាំងមួយផ្សេងទៀតនោះ ទាក់ទងទៅនឹងការយាយី និងការរើសអើងក្នុងកម្រិតមួយយ៉ាងខ្ពស់ ដែលអ្នកប្តូរភេទជាស្ត្រីធ្លាប់ទទួលរង គឺប្រព្រឹត្តឡើងដោយនគរបាល ដោយសារថាអ្នកឆ្លើយតបជាច្រើននាក់ធ្លាប់ត្រូវបានចាប់ខ្លួន និងឃុំខ្លួន ហើយជារឿយៗរងការរំលោភបំពានពីសំណាក់នគរបាលដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ។ ច្រើនជាងមួយភាគបី (**៣៩%**) នៃអ្នកឆ្លើយតប ធ្លាប់ត្រូវបានចាប់ខ្លួន ហើយ **៩២%** នៃអ្នកទាំងនេះជឿថាពួកគេត្រូវបានចាប់ខ្លួនដោយសារតែអត្តសញ្ញាណប្តូរភេទរបស់ពួកគេ។ ប្រមាណមួយភាគបី (**៣៤%**) ក្នុងចំណោមអ្នកឆ្លើយតបទាំងអស់បានរាយការណ៍ថារងការចោទប្រកាន់បទល្មើសដោយមិនត្រឹមត្រូវ។ ករណីធ្ងន់ធ្ងរផ្សេងមួយទៀតដែលមានលើកឡើងលម្អិតនៅក្នុងរបាយការណ៍ គឺការអនុវត្តដែលមិនធ្លាប់រាយការណ៍ពីមុនមកចំពោះអ្នកប្តូរភេទជាស្ត្រី ដែលរងការប្រមាថជាសាធារណៈ និងត្រូវបានបង្ខំឱ្យចុះងូតទឹកស្អឹងដោយនគរបាលមូលដ្ឋានមួយចំនួន ដែលជាការដាក់ទោសពិន័យក្រៅច្បាប់ ដែលអាចចាត់ទុកថាជាការធ្វើទារុណកម្មក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

ជនរងគ្រោះម្នាក់ដែលទទួលរងការប្រព្រឹត្តមកលើខ្លួនបែបនេះ បាននិយាយដោយសង្ខេបពីភាពអស់សង្ឃឹមរបស់អ្នកប្តូរភេទជាស្ត្រីចំពោះការស្វែងរកយុត្តិធម៌តាមរយៈប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជាយ៉ាងដូច្នេះថា៖ *«ខ្ញុំធ្លាប់ជួបប្រទះអំពើហិង្សាពីសំណាក់នគរបាលកាលពីមុន ប៉ុន្តែជាការពិតដែលខ្ញុំមិនបានទៅប៉ុស្តិ៍នគរបាលដើម្បីរាយការណ៍ករណីនោះទេ។ ខ្ញុំគិតថាវាគ្មានប្រយោជន៍ទេ ហើយគិតថាខ្ញុំមិនអាចឈ្នះក្តីនោះទេ។ ពួកគេមិនដែលយកចិត្តទុកដាក់នឹងពួកខ្ញុំឡើយ។ តែខ្ញុំចង់ឱ្យអំពើទាំងនោះត្រូវបញ្ឈប់។ ខ្ញុំចង់ឱ្យអាជ្ញាធរគោរពសិទ្ធិរបស់ស្រីស្រស់ និងបញ្ឈប់ការរំលោភបំពាននានាមកលើពួកខ្ញុំទៀត។»*

ស្របពេលដែលមន្ត្រីជាន់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាមួយចំនួន («រដ្ឋាភិបាល») មានបំណងបង្ហាញថាប្រទេសកម្ពុជាជាប្រទេសដែលស្វាគមន៍ស្ត្រីស្រលាញ់ ប្រុសស្រឡាញ់ប្រុស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទ («អ្នកស្រលាញ់ភេទដូចគ្នា») នៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះក្តី ការស្រាវជ្រាវនេះបង្ហាញពីស្ថានភាពជាក់ស្តែងដ៏គួរឲ្យបារម្ភ។ របកគំហើញនៃការស្រាវជ្រាវនេះ បង្ហាញថាការធ្វើទុក្ខបុកម្នេញទៅលើអ្នកប្តូរភេទជាស្ត្រី ត្រូវតែមានការយកចិត្តទុកដាក់ជាបន្ទាន់ ប្រសិនបើប្រទេសកម្ពុជាគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ខ្លួនមែននោះ។

ម.ស.ម.ក សូមស្នើរាជរដ្ឋាភិបាលកម្ពុជាមេត្តាដោះស្រាយបញ្ហាការរើសអើងដែលកាន់តែរាលដាលទៅលើអ្នកប្តូរភេទជាស្ត្រីជាបន្ទាន់ និងពិចារណាលើអនុសាសន៍លម្អិតដែលលើកឡើងនៅក្នុងរបាយការណ៍របស់ ម.ស.ម.ក រួមទាំងបង្កើតច្បាប់ដែលហាមប្រាមឱ្យបានច្បាស់លាស់ចំពោះការរើសអើងដោយសារអត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរភេទ។

របាយការណ៍នេះក៏បានផ្តល់ជាអនុសាសន៍បន្ថែមជូនដល់រដ្ឋាភិបាល មេត្តាដោះស្រាយការរំលោភបំពានដែលរីករាលដាលពីសំណាក់នគរបាលទៅលើសិទ្ធិរបស់អ្នកប្តូរភេទជាស្ត្រី ដោយត្រូវធ្វើការស៊ើបអង្កេតលើការចោទប្រកាន់ពីករណីរំលោភបំពានទាំងអស់ប្រព្រឹត្តឡើងដោយនគរបាល និងចាត់វិធានការផ្នែកវិន័យសមស្រប ព្រមទាំងបញ្ចូលការបណ្តុះ បណ្តាលអំពីសិទ្ធិមនុស្ស សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា និងការមិនរើសអើងក្នុងកម្មវិធីបណ្តុះបណ្តាល សម្រាប់សិក្ខាកាមជាមន្ត្រី នគរបាលទាំងអស់។

លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ ម.ស.ម.ក មានប្រសាសន៍ថា ៖

*«ការស្រាវជ្រាវនេះផ្តល់ការយល់ដឹងសំខាន់ថ្មីមួយផ្សេងទៀតចំពោះការរើសអើងដែលបានប្រឈមដោយអ្នកប្តូរភេទជាស្ត្រីនៅក្នុងជីវភាពប្រចាំថ្ងៃនៅក្នុងប្រទេសកម្ពុជា។ អ្នកប្តូរភេទជាស្ត្រីនៅកម្ពុជាប្រឈមនឹងការរឹតត្បិតឱកាសការងារ ការបដិសេធទទួលស្គាល់ពីក្រុមគ្រួសារ ព្រមទាំងរងការរំលោភបំពាន និងការយាយីពីសំណាក់នគរបាលក្នុងកម្រិតដ៏គួរឱ្យព្រួយបារម្ភជាខ្លាំង។ ទិន្នន័យទាំងនេះបង្ហាញពីភាពចាំបាច់ជាបន្ទាន់សម្រាប់រាជរដ្ឋាភិបាលក្នុងការចាត់វិធានការឱ្យបានឆាប់រហ័សដើម្បីការពារសិទ្ធិរបស់អ្នកប្តូរភេទជាស្ត្រី។»*

**សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់លោក នួន ស៊ីដារ៉ា អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ នៃ ម.ស.ម.ក តាមទូរសព្ទ +៨៥៥ (0) ៩៧៩ ៦៦៦ ៥៦៦ ឬ អ៊ីម៉ែល sidara.noun@cchrcambodia.org ឬ លោក ផាត ដឺប្រ៊ុន ទីប្រឹក្សាផ្នែកច្បាប់ នៃ ម.ស.ម.ក តាមរយៈទូរសព្ទ +៨៥៥ (0) ៨៩៥៣ ៦២១៥ ឬ អ៊ីម៉ែល pat.debrun@cchr.org ។**

បណ្ណាធិការៈ

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បង្កើតឡើងក្នុងខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ពន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសពលរដ្ឋនិងសិទ្ធិនយោបាយនៅក្នុងកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងអំពើទារុណកម្ម (OMCT) បណ្តាញប្រឆាំងអំពើទារុណកម្ម អែស អូ អែស សមាជិកនៃដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អាយហ្វិក) ដែលជាបណ្តាញសកលនៃសេរីភាពខាងបញ្ចេញមតិនិងសម្ពន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) និងជាសមាជិកនៃសម្ពន្ធពិភពលោកដើម្បីការចូលរួមរបស់ប្រជាពលរដ្ឋ ("CIVICUS") ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងបានទទួលពានរង្វាន់ទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនងនិងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសប៊េន ប្រទេសអូស្រ្តាលី។